# ចំណាប់អារម្មណ៍របស់តំណាងសិក្ខាកាមនៅក្នុងសិក្ខាសាលាស្តីពី
# «ការផ្សព្វផ្សាយលទ្ធផលវេទិកាពិភាក្សាអំពីស្ត្រី និងការចូលទៅកាន់ព័ត៌មាន»

ជាបឋម នាងខ្ញុំសូមគោរពលោកបណ្ឌិត Raymond Leos សមាជិកក្រុមប្រឹក្សាភិបាល និងជា ទីប្រឹក្សាជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋានរបស់រដ្ឋសភា។

លោក ភាព សុភា អ្នកពិគ្រោះការនៃគម្រោងអភិបាលកិច្ចល្អមូលដ្ឋាននៃក្រសួងមហាផ្ទៃ។

លោក ស្រីជឹម ម៉ាណាវី នាយិកាអង្គការវិទ្យាស្ថានបើកទូលាយ និង អស់ លោក លោកស្រី ដែលអញ្ជើញមកពីក្រសួងពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និង ក្រុមប្រឹក្សាឃុំ សង្កាត់ជាទីគោរព!

នាងខ្ញុំឈ្មោះសូ យ៉ាន ជាសមាជិកក្រុមប្រឹក្សាសង្កាត់កន្ទោក និងជាតំណាងសិក្ខាកាមដែលបានទទួលការបណ្តុះបណ្តាលពីរវគ្គស្ត្រីពី« សិទ្ធិទទួលព័ត៌មានប្រកបដោយទស្សនៈយេនឌ័រ» ដែលមានរយៈពេល២ថ្ងៃនៅខែមីនា និង «ការប្រើប្រាស់បច្ចេកវិទ្យា សារគមនាគមន៍ និងព័ត៌មានវិទ្យាក្នុងការទទួល និងផ្សព្វផ្សាយព័ត៌មាន» ដែលមានរយៈពេល៣ថ្ងៃនៅខែមិថុនា។ រៀបចំសហការដោយសម្ព័ន្ធ ភាពជាតិ ឃុំ សង្កាត់និងអង្គការវិទ្យាស្ថានបើកទូលាយ។

**គណៈអធិបតីជាទីគោរព អស់លោក លោកស្រីជាទីមេត្រី**!

ក្រោយពីបានទទួលការបណ្តុះបណ្តាល យើងខ្ញុំជាសិក្ខាកាមទាំងអស់មានទឹកចិត្តសប្បាយរីករាយ ក្នុងការទទួលបានចំណេះដឹងទាក់ទងទៅនឹង សិទ្ធិទទួលព័ត៌មានប្រកបដោយទស្សនៈយេនឌ័រ និងការប្រើប្រាស់បច្ចេកវិទ្យា សារគមនាគមន៍ និងព័ត៌មានវិទ្យាក្នុងការទទួល និងផ្សព្វផ្សាយព័ត៌មាន។

វគ្គបណ្តុះបណ្តាលនេះបានធ្វើឲ្យសិក្ខាកាមទាំងអស់ ទទួលនូវចំណេះដឹង និងបទពិសោធន៍ថ្មីៗដូចជា សិទ្ធិទទួលព័ត៌មាន ព័ត៌មានសាធារណៈ និងព័ត៌មានឯកជន សារសំខាន់នៃសិទ្ធិទទួលព័ត៌មាន តួនាទីភារកិច្ចរបស់អាជ្ញាធរ មូលដ្ឋាន ការបើកចំហព័ត៌មាន និងដែនកំណត់នៃការលើកលែង ក្របខណ្ឌគតិយុត្តិអំពីព័ត៌មានសាធារណៈនិងដែនកំណត់ រៀបចំផែនការសកម្មភាពដើម្បីលើកកម្ពស់សិទ្ធិទទួលព័ត៌មាន អ្វីជាដំណឹង និងអ្វី

ជាព័ត៌មាន តើរកដំណឹងនៅឯណា ការសរសេរបែបវិជ្ជាជីវៈនិងការសរសេរបែបបញ្ចេញបញ្ចូល ផែនការសរសេររឿង ការសរសេរព័ត៌មានខ្លីចេញពីយុទ្ធនាការ កិច្ចប្រជុំ ភាពខុសគ្នារវាងអត្ថបទព័ត៌មានរបស់អ្នកសារព័ត៌មាន និងអត្ថបទរបស់មន្ត្រីស្ថាប័នមួយ ការសរសេរលិខិតជូនដំណឹងដល់អ្នកសារព័ត៌មាន ច្បាប់និងក្រមសីលធម៌សម្រាប់អត្ថបទនិងរូបភាពដើម្បីជៀសវាងបណ្ដឹងតុលាការ និងការតវ៉ាពីប្រជាពលរដ្ឋ ការប្រើប្រាស់កុំព្យូទ័រជាភាសាខ្មែរ និងការស្វែងរកព័ត៌មានតាមអ៊ីនធឺណិតជាដើម។

វគ្គបណ្ដុះបណ្ដាលទាំងនេះ បានផ្ដល់ដល់យើងខ្ញុំជាក្រុមប្រឹក្សាសង្កាត់នូវចំណេះដឹងបន្ថែមដែលពីមុនមកមិនដែលបានទទួលចំណេះដឹងទាំងអស់នេះទាំងនេះទាក់ទងនឹងបច្ចេកវិទ្យា សិទ្ធិទទួលព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មានយើងខ្ញុំបានប្រើប្រាស់នូវចំណេះដឹងទាំងនេះសម្រាប់ការងារប្រចាំថ្ងៃឲ្យមានភាពប្រសើរឡើងនិងឆ្លើយតបទៅនិងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងឃុំសង្កាត់របស់យើងខ្ញុំ។
នាងខ្ញុំតំណាងសិក្ខាកាមទាំងអស់សូមថ្លែងអំណរគុណដល់សម្ព័ន្ធភាពជាតិ ឃុំ សង្កាត់ និងអង្គការវិទ្យាស្ថានបើក ដែលខិតខំយកចិត្តទុកដាក់ បើកវគ្គបណ្ដុះបណ្ដាលជូនដល់មន្ត្រីឃុំសង្កាត់ ក្រសួង និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការទទួលចំណេះដឹងទាំងអស់នោះ។

នាងខ្ញុំក៏សូមគោរពជូនពរអង្គការវិទ្យាស្ថានបើកទូលាយនៅមានដំណើរការដើម្បីបើកវគ្គបណ្ដុះបណ្ដាលដល់មន្ត្រីឃុំ សង្កាត់បន្តទៀត។ជាទីបញ្ចប់នាងខ្ញុំសូមគោរពជូនពរដល់គណៈអធិបតី អស់លោកលោកស្រីទាំងអស់ ជួបប្រទះតែសេចក្ដីសុខ និង ពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈពលៈកុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!